# សុន្ទរកថាស្វាគមន៍

## របស់បណ្ឌិត ជា ទុធណា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងវគ្គបណ្តុះបណ្តាលស្តីពី

**“សវនកម្មផ្អែកលើហានិភ័យ, ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មានទូទៅ, សវនកម្មសមិទ្ធកម្ម និងរបាយការណ៍សវនកម្ម”**

សណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូកេត្រា ថ្ងៃទី១៦-១៩ ខែធ្នូ ឆ្នាំ២០១៩

រាជធានីភ្នំពេញ

- សូមគោរព លោកស្រី **Kristine Leah Mercado,** លោកស្រី Katrina Fano និងលោក **Arnold Agnila** សវនករជាន់ខ្ពស់ការិយាល័យអគ្គសវនករ, ធនាគារអភិវឌ្ឍន៍អាស៊ី, ទីក្រុងម៉ានីល
- សូមគោរព លោក អ៊ូច ចំរើន មន្ត្រីកម្មវិធីជាន់ខ្ពស់នៃស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី មិត្តសវនករកម្ពុជា ជាទីគោរព!

**១-** ខែនេះ ឆ្នាំមុន ២០១៨ យើងបានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី ក្រោមប្រធានបទចំនួនបួន គឺ សវនកម្មផ្ទៃក្នុងផ្អែកលើហានិភ័យ, ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មានទូទៅ, សវនកម្មសមិទ្ធកម្ម, និងការសរសេររបាយការណ៍សវនកម្ម ដែលត្រូវបានរៀបចំឡើង ដោយការិយាល័យអគ្គសវនករនៃធនាគារអភិវឌ្ឍន៍អាស៊ី។ ដោយឡែកថ្ងៃនេះ ជាថ្មីម្តងទៀត យើងបានមកជួបជុំគ្នាទទួលការបណ្តុះបណ្តាលបន្ថែម លើប្រធានបទដ៏សំខាន់នេះ តែសម្រាប់មិត្តសវនករកម្ពុជា ពីក្រសួងចំនួន៦ ផ្សេង គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម,ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, ក្រសួងផែនការ, ក្រសួងយុត្តិធម៌, និងក្រសួងទេសចរណ៍។ ឆ្លៀតឱកាសដ៏រីករាយនេះ សូមអនុញ្ញាតឱ្យខ្ញុំតំណាងមិត្តសវនករទាំងអស់ ដែលទទួលបុព្វសិទ្ធិ (Privilege) និងមានវត្តមាននៅទីនេះ សំដែងនូវកិច្ចស្វាគមន៍ និងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះការិយាល័យអគ្គសវនករនៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានបន្តយកចិត្តទុកដាក់ជួយពង្រឹងសមត្ថភាពដល់សវនករផ្ទៃក្នុងកម្ពុជា។

**២-** សូមអនុញ្ញាតឱ្យខ្ញុំរំលឹកនូវការរួមចំណែកដ៏ថ្លៃថ្លា របស់ធនាគារអភិវឌ្ឍន៍អាស៊ីចំពោះកម្ពុជា។ ត្រឹមខែ

តុលា ឆ្នាំ២០១៩ ទំហំហិរញ្ញប្បទានសរុប ត្រូវបានរាយការណ៍ស្មើនឹង ៣,៣៦ ប៊ីលានដុល្លារអាមេរិក ក្នុងនោះ ហិរញ្ញប្បទានឥតសំណងមានចំនួន ៤៩៨លានដុល្លារអាមេរិក។ ដោយឡែក មុខងារសវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាអ្នកទទួលចំណែកពីហិរញ្ញប្បទាននេះដែរ ត្រូវបានចាប់ផ្តើមបង្កើតជាហូរហែ ពីឆ្នាំ២០០៥ មក ហើយធនាគារអភិវឌ្ឍន៍អាស៊ីអាចចាត់ទុកជាស្ថាបនិកចំបងមួយ ដែលបានផ្តល់នូវជំនួយបច្ចេកទេសសម្រាប់បង្កើត និងពង្រឹងសមត្ថភាពសវនកម្មផ្ទៃក្នុងមកទល់បច្ចុប្បន្ន។ ជំនួយបច្ចេកទេសពីស្ថាប័នអន្តរជាតិនេះ បើនិយាយតែលើការជួយកសាងគ្រឹះបទដ្ឋានគតិយុត្ត និងមូលដ្ឋានបច្ចេកទេសសវនកម្មផ្ទៃក្នុង (មិនរំលឹកពីទស្សនកិច្ចសិក្សា វគ្គបណ្តុះបណ្តាលក្នុងនិងក្រៅ សម្ភារៈ និងការបណ្តុះបណ្តាលដូចថ្ងៃនេះ) គឺសម្រេចបានចំនួនបីលើក (រាប់តែលើកដែល កសហវ ចូលរួម) រួចមកហើយ គឺលើកទី១ ចន្លោះចុងឆ្នាំ ២០០៤-២០០៥ (Nihal Fernando Pule& Sok keoreaksmey) បានជួយរៀបចំៈ អនុក្រឹត្យលេខ ៤០, ស្តង់ដាសវនកម្មផ្ទៃក្នុង, ក្រមសីលធម៌សម្រាប់វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង និងគោលការណ៍គ្រប់គ្រងផ្ទៃក្នុង, លើកទី២ ក្នុងអំឡុងឆ្នាំ ២០០៩-២០១១ (Danilo Cabug & Long atichbore) បានជួយរៀបចំនីតិវិធីសវនកម្មផ្ទៃក្នុងលម្អិត ដែលក្លាយជាមូលដ្ឋាននៃសៀវភៅណែនាំសវនកម្មផ្ទៃក្នុង (បានបោះពុម្ពនិងចែកចាយរួចជូនក្រសួង ស្ថាប័ន) និងលើកទី៣ ក្នុងឆ្នាំ២០១៩ បានផ្តោតលើកការធ្វើសវនកម្មសមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាន ដែលបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយ នៃការរៀបចំចេញផ្សាយគោលការណ៍ណែនាំសវនកម្មលើសមិទ្ធកម្ម និងលើបច្ចេកវិទ្យាព័ត៌មាន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តសវនករ ជាទីរាប់អាន** !

**៣-** ជាសត្យានុម័ត អង្គភាពមួយអាចសម្រេចគោលដៅរបស់មុខងារតាមការកំណត់ ដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពពេញលេញ លុះត្រាតែសម្រេចបានទាំងព្រម នូវគោលដៅនៃដំណើរការចំបងផង និងគោលដៅនៃដំណើរការគាំទ្រផ្សេងៗផង។ នៅពេលរៀបចំដំណើរការនីមួយៗ ថ្នាក់ដឹកនាំអង្គភាព តែងតែបំពាក់នូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាឱ្យដំណើរការប្រព្រឹត្តទៅដោយរលូន អាចដោះស្រាយឧបសគ្គបានទាន់ពេល និងអាចផលិតបាននូវទំនិញ និងសេវាតាមការរំពឹងទុក។ ក៏ប៉ុន្តែ នៅក្នុងបរិការណ៍ប្រកបដោយភាពវិជ្ជលរបស់កត្តាក្នុងនិងក្រៅ ពីមនុស្ស បច្ចេកវិទ្យា នយោបាយ ។ល។ និង។ល។ គោលដៅដែលបានព្រៀងទុករបស់ដំណើរការនីមួយៗ អាចនឹងពុំសម្រេចបានតាមការកំណត់។ ហេតុនេះ ថ្នាក់ដឹកនាំអង្គភាពត្រូវតាមដានឃ្លាំមើលប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃដំណើរការនីមួយៗ ដើម្បីធ្វើបច្ចុប្បន្នភាព និងពង្រឹងកិច្ចប្រតិបត្តិបន្ថែមតាមការចាំបាច់។ ក៏ប៉ុន្តែ ជាសត្យានុម័ត និងអត្តនោម័ត អង្គភាពពុំអាចរក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងប្រតិបត្តិការបានរឹងមាំ ដោយខ្លួនឯងបានគ្រប់ពេលវេលាបានឡើយ ជាហេតុធ្វើឱ្យអង្គភាពអាចស្ថិតក្នុងស្ថានភាពអាក្រក់ជាយថាហេតុ។ ប្រការនេះទាមទារឱ្យមានភាគីទី៣ ឬហៅថាបន្ទាត់ការពារទី៣/ សវនកម្មផ្ទៃក្នុងមកជួយថ្នាក់ដឹកនាំ ដើម្បីផ្តល់អនុសាសន៍ពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លុបបំបាត់ចំណុចខ្វះខាត ពង្រឹងការគ្រប់គ្រងហានិភ័យ ធានាអនុលោមភាព និងប្រសិទ្ធភាពប្រតិបត្តិការឈានទៅសម្រេចគោលដៅទាំងឡាយដែលអង្គភាពបានកំណត់។

**៤-** វិសាលភាពធំធេង ស្មុគស្មាញនិងប្រទាក់ក្រឡានៃមុខងារ និងដំណើរការរបស់អង្គភាពរងសវនកម្ម ព្រមទាំងកំហិតនៃធនធានសាធារណៈ ជាមនុស្ស ថវិកា និងពេលវេលា ខណៈដែលឆន្ទៈនិងការប្តេជ្ញាត្រូវបានសម្រួចឆ្ពោះទៅរកគុណភាពនិងប្រសិទ្ធភាព សវនករផ្ទៃក្នុងចាំបាច់ត្រូវតែធ្វើការផ្អែកលើមូលដ្ឋានហានិភ័យ។ ដូច្នេះ ថាតើហានិភ័យអាចកំណត់បានដូចម្តេច? នៅពេលណា? នៅកន្លែងណា? ដោយប្រើវិធីសាស្ត្រ និងនីតិវិធីអ្វី? និងថាតើត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយហានិភ័យដែលបានរកឃើញ និងបង្កា ទប់ស្កាត់កុំឱ្យហានិ-ភ័យកើតឡើង? ម្យ៉ាងទៀត នៅពេលអង្គភាពកាន់តែអេឡិចត្រូនិក និងឌីជីថលឡើង តើមុខងារសវនកម្មនឹងប្រែប្រួលទៅជាយ៉ាងណា? តើចរឹកហានិភ័យអាចផ្លាស់ប្តូរឬទេ? តើការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងងាយស្រួលឬលំបាកជាងមុន? ឧទាហរណ៍នៅពេលរដ្ឋបាលសាធារណៈ កាន់តែពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មានពិសេសនៅក្នុងយុគសម័យ 4th Industrial Revolution ដែល Economy កាន់តែ Digital, Government កាន់តែ Electronique, មានការកសាង New Platform, Big Data, Block Chain រួមទាំងការប្រើ AI, Robotic,... ជាដើម។

**៥-** ជាការពិត អង្គភាពអាចសម្រេចបាននូវគោលដៅរួមបានកំណត់ តែមិនច្បាស់ថាមធ្យោបាយដែលប្រើប្រាស់ជាមធ្យោបាយដែលសមស្រប និងមានតម្លៃទាប ដែលអាចប្រើធាតុចូល ដោយសន្សំសំចៃ និងផលិតចេញនូវផល ក្នុងបរិមាណ និងគុណភាព ប្រហាក់ប្រហែលនិងអង្គភាពដូចគ្នាកម្រិតឧត្តមានុវត្តដែរឬទេ។ នេះជាសនិទានកម្ម (Rational)មួយទៀត ដែលអង្គភាពសាធារណៈភាគច្រើនមិនទាន់យកចិត្តទុកដាក់នៅឡើយ។ អាស្រ័យហេតុនេះហើយ ទើបដំណាក់កាលទី៤ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "**គណនេយ្យភាពសមិទ្ធកម្ម**" របស់រាជរដ្ឋាភិបាលកម្ពុជា ក្លាយជាគោលដៅចុងក្រោយ ដែលត្រូវសម្រេចឱ្យបានតាមការគ្រោងទុកនៅឆ្នាំ២០២៥។ នៅពេលនោះ ថវិកាកម្ពុជានឹងក្លាយជាថវិកាព័ត៌មានសមិទ្ធកម្ម ជាថវិកាផ្អែកលើធាតុចេញ និងវិមជ្ឈការ។ ការនេះ ទាមទារនូវយន្តការត្រួតពិនិត្យបន្ថែម ដើម្បីបញ្ជាក់និងផ្ទៀងផ្ទាត់ថាការគ្រប់គ្រងចំណាយនិងចំណូល និងសកម្មភាពគាំទ្រនានា មានគោលដៅត្រឹមត្រូវ បានប្រើមធ្យោបាយសមស្រប អនុញ្ញាតឱ្យមានការសន្សំសំចៃ ធានាបានប្រសិទ្ធភាព និងហុចបច្ច័យតាមការរំពឹងទុកដោយពុំបង្កការលំបាកឬរាំងស្ទះដល់សកម្មភាពដទៃទៀត។ នេះជាប្រភេទត្រួតពិនិត្យថ្មី ដែលហៅថាសវន-កម្មសមិទ្ធកម្ម និងដែលសវនករផ្ទៃក្នុងយើងពុំទាន់យល់ស៊ីជំរៅ និងពុំទាន់ធ្លាប់អនុវត្តនៅឡើយ។

**អង្គបណ្ណុះបណ្តាល ជាទីមេត្រី** !

**៦-** ការកំណត់ទីសវនកម្មមានហានិភ័យបានត្រឹមត្រូវ ការរកឃើញចំណុចខ្សោយ ការកំណត់ឫសគល់បញ្ហា ការវិភាគបច្ច័យ ការផ្តល់អនុសាសន៍ និងការបង្ហាញលទ្ធភាពសន្សំសំចៃ បង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពលើដំណើរការណាមួយ ជាការលំបាកណាស់ទៅហើយ ក៏ប៉ុន្តែ គមនាគមន៍ជាមួយសវនដ្ឋានឱ្យបានផលល្អ រឹតតែមានការលំបាក ពិសេសជាលាយលក្ខណ៍អក្សរ។ សវនករត្រូវពិចារណាក្នុងការរៀបចំឃ្លាឃ្លោង និងការថ្លឹងថ្លែងលើការប្រើប្រាស់ពាក្យពេជន៍ ពិសេសស័ព្ទបច្ចេកទេសយ៉ាងណា ដើម្បីជណ្តើមការចាប់

អារម្មណ៍ និងអនុញ្ញាតឱ្យសវនដ្ឋានអាចទទួលយក ឬទទួលយកដោយមិនដឹងខ្លួន ដោយរក្សាបាននូវខ្លឹមសារស្នូល និងមិនប៉ះពាល់ដល់គោលបំណងអនុសាសន៍សវនកម្ម។ ទោះជាយើងបានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលស្ដីពីប្រធានបទទាំងនេះ និងបានសរសេររបាយការណ៍សវនកម្មជាច្រើនមកហើយក្ដី ក៏យើងនៅតែត្រូវការស្វែងយល់បន្ថែមទៀត ឱ្យកាន់តែបានស៊ីជម្រៅនិងច្បាស់លាស់ រួមទាំងរង់ចាំទទួលនូវការណែនាំថ្មីៗនិងបទពិសោធន៍ល្អៗ នៅក្នុងការរៀបចំ ចែកចាយនិងតាមដានរបាយការណ៍សវនកម្ម ដូចមានពាក្យពោលថា "រំលឹកមេរៀនជាបិតានៃការសិក្សា" និង "រៀន រៀន រៀន"។

**៧-** ដូច្នេះ បញ្ហាទាំង៤ ខាងលើ ដែលបានបរិយាយ និងចោទសួរ តែពុំទាន់មានចម្លើយឬដំណោះស្រាយនោះ យើងទាំងអស់គ្នានឹងអាចរកឃើញ នៅក្នុងវគ្គបណ្ដុះបណ្ដាលរយៈពេលបួនថ្ងៃនេះជាមួយគ្នា។ អាស្រ័យហេតុនេះ ខ្ញុំសូមស្នើដល់សិក្ខាកាមមេត្តាខិតខំត្រងត្រាប់ ពិគ្រោះ និងចោទសួរជម្រះចម្ងល់ ទាក់ទងនឹងប្រធានបទខាងលើឱ្យបានផុសផុល និងជឿជាក់ថាវគ្គបណ្ដុះបណ្ដាលរបស់យើង នឹងសម្រេចលទ្ធផលបានល្អប្រសើរ។

**៨-** ជាថ្មីម្ដងទៀត ខ្ញុំសូមតំណាងឱ្យសវនករជាសិក្ខាកាមដែលមានវត្តមាននៅទីនេះ សូមសំដែងនូវការអរគុណ និងដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា, ពិសេសចំពោះឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានជំហរឥតងាករេ ក្នុងការជ្រោងមុខងារសវនកម្មផ្ទៃក្នុង ឱ្យកាន់តែឈានខ្ពស់ឡើងថែមទៀត។ យើងខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការិយាល័យអគ្គសវនករនៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានឆ្លៀតពេលវេលាមកចែករំលែកចំណេះដឹង និងចំណេះធ្វើតាមរយៈវគ្គបណ្ដុះបណ្ដាលលើប្រធានបទដ៏មានសារៈសំខាន់នេះ ព្រមទាំងសង្ឃឹមយ៉ាងមុតមាំថា ការិយាល័យអគ្គសវនករ នឹងបន្តរៀបចំវគ្គបណ្ដុះបណ្ដាលលើប្រធានបទថ្មីៗជារៀងរាល់ឆ្នាំ នៅទីនេះ ឬកន្លែងផ្សេង ដើម្បីបន្តពង្រឹងសមត្ថភាពសវនកម្មផ្ទៃក្នុងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាចុងក្រោយ តែជាអង្គភាពដែលមិនអាចខ្វះបាន យើងខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា និងដោយឡែកចំពោះលោក **អ៊ូច ចំរើន** មន្ត្រីគម្រោងជាន់ខ្ពស់ ដែលតែងតែបានយកចិត្តទុកដាក់ ជួយជ្រោមជ្រែងបញ្ចូលមុខងារសវនកម្មផ្ទៃក្នុង ទៅក្នុងគម្រោងពង្រឹងសមត្ថភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងជំរុញការអនុវត្តប្រកបដោយជោគជ័យជារៀងរាល់លើក។

**៩-** ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរ **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា មិត្តសវនករ** សូមមានសុខភាពល្អ បរិបូណ៌ និងប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ។